# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦

## ការចូលជាធរមាននៃកិច្ចព្រមព្រៀងសេវាដឹកជញ្ជូនតាមផ្លូវអាកាស រវាងជប៉ុន និងកម្ពុជា

នៅថ្ងៃទី២៦ ខែឧសភា "កិច្ចព្រមព្រៀងរវាងប្រទេសជប៉ុន និងប្រទេសកម្ពុជាស្តីពីសេវាដឹកជញ្ជូនតាមផ្លូវអាកាស" (កិច្ចព្រមព្រៀងសេវាអាកាសចរណ៍ជប៉ុន-កម្ពុជា) បានចូលជាធរមានតាមរយៈការផ្លាស់ប្តូរកំណត់ទូតជូនដំណឹងជាផ្លូវការ អំពីការអនុម័តកិច្ចព្រមព្រៀងនេះ តាមនីតិវិធីរដ្ឋធម្មនុញ្ញ នៃប្រទេសជប៉ុន និងប្រទេសកម្ពុជា។

ជប៉ុននិងកម្ពុជាបានឯកភាពឲ្យមានការចរចារជាផ្លូវការអំពីកិច្ចព្រមព្រៀងសេវាអាកាសចរណ៍ជប៉ុន-កម្ពុជាក្នុងកិច្ចប្រជុំកំពូលជប៉ុន-កម្ពុជាកាលពីខែធ្នូឆ្នាំ២០១៣ ហើយខ្លឹមសារនៃកិច្ចព្រមព្រៀងនេះត្រូវបានឯកភាពគ្នាទាំងស្រុងនៅខែមិថុនា ឆ្នាំ២០១៤។ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៥ ឯកឧត្តម គូម៉ាម៉ារូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម ម៉ៅ ហាវណ្ណាល់ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិល នៃ ព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀមនៅប្រទេសកម្ពុជា។ បន្ទាប់មក កិច្ចព្រមព្រៀងនេះត្រូវបានអនុម័តដោយរដ្ឋសភាជប៉ុននៅថ្ងៃទី១៥ខែមេសា ឆ្នាំ២០១៦។

ក្នុងគោលបំណងបង្កើតឲ្យមានក្របខណ្ឌច្បាប់មួយដើម្បីបើកផ្លូវហោះហើរជាប្រក្រតី និងបង្កើតឲ្យមានស្ថេរភាពនៃការប្រតិបត្តិ ការហោះហើរជាប្រក្រតីរវាងប្រទេសជប៉ុន និងប្រទេសកម្ពុជា កិច្ចព្រមព្រៀងនេះ បានផ្តល់ផលប្រយោជន៍ទៅវិញទៅមកឲ្យប្រទេសទាំងពីរ ដែលរួមមានការផ្តល់ឲ្យគ្នានូវសិទ្ធិប្រតិបត្តិការហោះហើរជាប្រក្រតី និងការដាក់បញ្ញត្តិលើការលើកលែងពន្ធគយ គោលការណ៍កំណត់សំណុំដឹកជញ្ជូន នីតិវិធីកំណត់តម្លៃសំបុត្រយន្តហោះ និងការធានាការគ្រប់គ្រងសុវត្ថិភាព និងសន្តិសុខអាកាសចរណ៍។ យើងរំពឹងថា កិច្ចព្រមព្រៀងនេះនឹងអនុញ្ញាតិឲ្យមានស្ថេរភាពនៃដំណើរការហោះហើរជាប្រក្រតីរវាងប្រទេសជប៉ុន និងប្រទេសកម្ពុជាដែលនឹងជំរុញឲ្យមានការធ្វើដំណើររវាងប្រជាជាតិទាំងពីរ និងការដោះដូរពាណិជ្ជកម្មកាន់តែទូលំទូលាយ។

* នេះជាការបកប្រែក្រៅផ្លូវការ។ កាលបរិច្ឆេទដែលបានបញ្ជាក់ខាងលើគឺជាកាលបរិច្ឆេទចេញសេចក្តីប្រកាសដើមជាភាសាជប៉ុន។

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ: ០២៣-២១៧-១៦១ ទូរសារ: ០២៣-២១៤-៣៣០*
*អ៊ីមែល: eco.jpn@.pp.mofa.go.jp*
*គេហទំព័រ: http://www.kh.emb-japan.go.jp*